# សេចក្តីជូនដំណឹង

## ស្តីពី

## លទ្ធផលនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២២ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិក និងសាធារណជន មេត្តាទទួលជ្រាបថា កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២២ តាមរយៈ Video Con-Call របស់ធនាគារ អេស៊ីលីដា នៅ**ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២** នៅម៉ោង**១៤:០០នាទី ដល់ម៉ោង ១៦:០០នាទី** មានកូរ៉ុមចំនួន**៩៥,៨៥**ភាគរយ និងភាគហ៊ុនិកចូលរួមចំនួន**១៣០**នាក់ ស្មើនឹង**៤១៣.៨៦៩.៧៧៨**ភាគហ៊ុន។

ភាគហ៊ុនិកបានពិនិត្យ ពិភាក្សា និងអនុម័តដូចខាងក្រោម៖

១. អនុម័តការបែងចែកភាគលាភជាសាច់ប្រាក់ចំនួន៣៥ភាគរយ នៃប្រាក់ចំណេញក្នុងការិយបរិច្ឆេទ ដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ចំនួន៦៧៩.០០២.២៤០.០០០រៀល ស្មើនឹង២៣៧.៦៥០.៧៧៥.៣២៥,៦៧រៀល ក្នុងអត្រា៥៤៨,៦៤០៥រៀល ក្នុង១ភាគហ៊ុន និងរក្សាប្រាក់ចំណេញនៅសល់ក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុករបស់ធនាគារ អេស៊ីលីដា ដែលនឹងត្រូវអនុម័តចុងក្រោយដោយនិយ័តករ។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៣ ភាគរយ***។

២. អនុម័តគោលការណ៍ភាគលាភ។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩៣ ភាគរយ***។

៣. អនុម័តការតែងតាំងលោក Kyosuke Hattori ជាអភិបាលនៅធនាគារ អេស៊ីលីដា សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩២ ភាគរយ***។

៤. អនុម័តជ្រើសរើស និងតែងតាំង Grant Thornton (“GT”) ជាសវនករឯករាជ្យរបស់ធនាគារ អេស៊ីលីដា សម្រាប់ឆ្នាំហិរញ្ញវត្ថុ២០២៣។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩១ ភាគរយ***។

៥. អនុម័តការដំឡើងលាភការជូនប្រធានក្រុមប្រឹក្សាភិបាលដូចខាងក្រោម៖

- ដំឡើងលាភការជូន លោក ឆាយ សឿន ប្រធានក្រុមប្រឹក្សាភិបាល ដោយទទួលបានចំណាត់ថ្នាក់ “A+” ដែលមានប្រសិទ្ធភាពអនុវត្តប្រតិសកម្ម ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២។
- បូកបន្ថែមអត្រាអតិផរណាប្រចាំឆ្នាំ២០២១ ចំនួន២,៩០ភាគរយ លើលាភការរបស់ប្រធានក្រុមប្រឹក្សាភិបាល ដែលមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។ និង
- កែតម្រូវអត្រាអតិផរណាប្រចាំឆ្នាំ២០២០ ដោយបូកបន្ថែមលើលាភការរបស់ប្រធានក្រុមប្រឹក្សាភិបាលដែលមានប្រសិទ្ធភាពប្រតិសកម្ម ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២។

***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៨៩ ភាគរយ***។

៦. អនុម័តការកែតម្រូវកម្រៃសេវា សម្រាប់ក្រុមប្រឹក្សាភិបាល ស្របតាមអត្រាអតិផរណាប្រចាំឆ្នាំ២០២១ ចំនួន២,៩០ភាគរយ។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៨៩ ភាគរយ***។

៧. អនុម័តកាលបរិច្ឆេទកំណត់ទុកថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២ សម្រាប់កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ។ ***ភាគហ៊ុនិកទាំងអស់បានបោះឆ្នោតគាំទ្រដោយសម្លេង ៩៩,៩១ ភាគរយ***។

ថ្ងៃអង្គារ ៣កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP